# សាធារណរដ្ឋប្រជាមានិតកម្ពុជា

ក្រសួងយុត្តិធម៌

លេខ ៣៣៩ ស្នួន រប-៩៣

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ភ្នំពេញ ថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៣

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

-ប្រធានតុលាការ អយ្យការ ខេត្ត-ក្រុង

**កម្មវត្ថុ:** អំពីក្របខ័ណ្ឌតុលាការ អយ្យការ ខេត្ត-ក្រុង

ខ្ញុំសូមជម្រាបលោកប្រធានតុលាការ អយ្យការខេត្ត-ក្រុង បច្ចុប្បន្ននេះក្រសួងយុត្តិធម៌ពុំបានទទួលការណ៍ណែនាំពីរដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា ស្តីពីការកំណត់ក្របខ័ណ្ឌរបស់តុលាការ អយ្យការខេត្ត-ក្រុង នៅឡើយទេ ប៉ុន្តែតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា ដែលបានប្រកាសឲ្យប្រើតាមក្រឹត្តលេខ០៦ ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ របស់ក្រុមប្រឹក្សារដ្ឋ ក្របខ័ណ្ឌរបស់តុលាការ អយ្យការខេត្ត-ក្រុង ដូចជា ចៅក្រម រដ្ឋអាជ្ញា ក្រឡាបញ្ជី និយាយរួមគឺការផ្លាស់ប្តូរ តែងតាំង តម្លើងឋានន្តរសក្តិ ហូតងារ គឺតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងដោយរដ្ឋមន្ត្រីយុត្តិធម៌ជាអ្នកសម្រេច ។

ដូចនេះចាប់ពីពេលនេះតទៅ ការទទួលយក ឬក៏ការផ្លាស់ចេញបុគ្គលិកក្នុងក្របខ័ណ្ឌតុលាការ អយ្យការខេត្ត-ក្រុង ឬការខ្វះខាតកម្មាភិបាលបុគ្គលិកចាំបាច់ត្រូវសុំយោបល់សម្រេចពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាមុនសិន បើពុំនោះទេ ក្រសួងយុត្តិធម៌មិនទទួលខុសត្រូវចំពោះផលលំបាកដែលអាចកើតមានឡើងនាពេលខាងមុខនេះឡើយ ។

**រដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ចែម ស្នួន**

ចម្លើងជូន

-ក្រុមប្រឹក្សារដ្ឋមន្ត្រី

-ក្រសួងហិរញ្ញវត្ថុ

-គណៈកម្មាធិការខេត្ត-ក្រុង